00210150

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

D54/V/4

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៧)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ៧ សីហា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 08 / 2008
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# សេចក្តីសម្រេចចំពោះការបញ្ជាក់លើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលប្តឹងប្រឆាំង ចំពោះការចាត់តាំងអ្នកជំនាញ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្តី**

សុន អរុណ
Michiel PESTMAN
Victor KOPPE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / 08 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00210151



D54/V/4

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) កត់សម្គាល់ឃើញមាន“បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំចាត់តាំងអ្នកជំនាញ” ដែលលោក នួន ជា បានដាក់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ (“បណ្តឹងឧទ្ធរណ៍”)។

២. អនុលោមតាមវិធាន ៧៧(៣)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវធ្វើការកំណត់កាលបរិច្ឆេទសវនាការបន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ។[១]

៣. ប៉ុន្តែ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុង“សេចក្តីសន្និដ្ឋានតបចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ស្តីពីការចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃសម្បទារបស់គាត់ក្នុងការជំនុំជម្រះ” សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះ “គឺជាករណីសមស្របក្នុងការយកមកសម្រេចដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដោយមិនចាំបាច់រៀបចំសវនាការជេញដោល។”[២]

៤. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ សហមេធាវីការពារក្តីធ្វើការជូនដំណឹងដល់អង្គបុរេជំនុំជម្រះក្នុងលក្ខណៈមួយមិនផ្លូវការថា ពួកគេយល់ស្របទៅនឹងការលើកឡើងនេះ។

៥. អង្គបុរេជំនុំជម្រះពិចារណាឃើញថា បញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ សមស្របនឹងយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

៦. បន្ទាប់ពីធ្វើការពិចារណាអំពីការយល់ឃើញរបស់សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តីរបស់ជនត្រូវចោទ (“ភាគី”) អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះត្រូវយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

៦. អនុលោមតាមមាត្រា ៨(៤)នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអ.វ.ត.ក សំណើឆ្លើយតបចំពោះសារណា នឹងត្រូវអនុញ្ញាត ក្នុងករណីដែលមិនមានអំណះអំណាងជេញដោលដោយផ្ទាល់មាត់។[៣]

---

[១] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី ១) ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨។

[២] សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ស្តីពីការចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃសម្បទារបស់ខ្លួនក្នុងសវនជំនុំជម្រះ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ D54/V/2 វាក្យខណ្ឌទី៤។

[៣] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី២។

D54/V/4

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច និងណែនាំ:

(១) បណ្តឹងឧទ្ធរណ៍នឹងធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានតបរបស់ភាគីតែប៉ុណ្ណោះ។

(២) អនុញ្ញាតឱ្យជនត្រូវចោទដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេលប្រាំ(៥)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**